# ដំណាំឆៃថាវ

## I. ស្ថានភាពទូទៅ

ដំណាំស្ពៃមើម ឬដំណាំឆៃថាវជាប្រភេទដំណាំម្យ៉ាងដែលមានប្រជាប្រិយយ៉ាងខ្លាំងនៅក្នុងការប្រើប្រាស់ជាម្ហូបអាហារប្រចាំថ្ងៃ។ ក្នុងការបរិភោគគេអាចច្នៃចេញជាពីរប្រភេទគឺៈ មើមឆៅ ឬចំអិនដំណាំនេះមានប្រភពកំនើតមកពីប្រទេសចិន គេបានប្រើប្រាស់វាតាំងពីយូរយារណាស់មកហើយយើងអាចយកវាទៅកែច្នៃធ្វើជាជ្រក់ ឆៃប៉ូវ ជាដើមក្នុងទំងន់១០០ក្រាម ដែលបរិភោគ (មើម) សារធាតុសំខាន់ៗជាច្រើនដូចជាៈ



| បរិភោគ | ថាមពល | ទឹក% | ប្រូតេអ៊ីន | ខ្លាញ់ | កាបូអ៊ីដ្រាត | ជាតិសរសៃ | ផេះ |
|---|---|---|---|---|---|---|---|
| ដើមស្រស់ | ២៦ | ៩២.៦ | ១ | ០.២ | ៥.៦ | ១.៣ | ០.៦ |
| មើមចំអិន | ១៩ | ៩៤.៥ | ០.២ | ០.៤ | ៤K ៧ | ០០ | ០.៥ |
| បរិភោគ | Ca mg | P mg | Fe mg | Na mg | K mg | Bo mg | B mg |
| ដើមស្រស់ | ៣២ | ៣៤ | ១.០ | ១០ | ២៤២ | ០.០៤ | ២៦ |
| មើមចំអិន | ៤០ | ២.២ | ០.២ | ០០ | ០០ | ០.០៣ | ១៩ |





## II. បច្ចេកទេសដាំដុះ

ដើម្បីឆ្លើយតបទៅនឹងការដាំដុះលូតលាស់ ព្រមទាំងទទួលបានទិន្នផលខ្ពស់មានលក្ខខណ្ឌជាច្រើនដែលតំរូវឱ្យធ្វើការជ្រើសរើសដូចជាៈ

**១-អំពីរដូវកាលៈ** ឆៃថាវជាប្រភេទដំណាំដែលអាចដុះលូតលាស់មិនប្រកាន់រដូវ គេអាចដាំបានស្ទើរពេញ១ឆ្នាំនៅក្នុងតំបន់ក្តៅ (Tropic)។ ប៉ុន្តែការជ្រើសរើស រដូវវាមានទំនាក់ទំនងទៅនឹងសត្វល្អិតចង្រៃស៊ីបំផ្លាញព្រមទាំងធ្វើឱ្យទិន្នផលថយចុះ សីតុណ្ហភាពសមស្របបំផុតចន្លោះពី២០-២៥ °C កាលណាកើនពី ២៥-៣០°C ការផ្តល់ទឹកបានច្រើន ទើបទទួលបានទិន្នផលល្អ។នៅប្រទេសកម្ពុជាគេអាចដាំដុះបានល្អនៅរដូវទឹកសំរកចាប់ពី

ខែ តុលា ដល់ខែ មករា កាលណា ពន្យារពេលរហូតដល់ កុម្ភៈ ឬមិនា តែងទទួលរងនូវការបំផ្លាញ ពីសត្វល្អិតចង្រៃ ជាច្រើន ។

## ២-ការជ្រើសរើសពូជ

ដំណាំប្រភេទនេះមិនអាចផលិតពូជ នៅក្នុងប្រទេសយើងបានឡើយ ដូចនេះ ពូជសុទ្ធតែនាំមកពីប្រទេសនានាក្នុងតំបន់អាស៊ី ដែលផលិតដោយក្រុមហ៊ុនជាច្រើន ហើយត្រូវបានពិសោធន៍ វាយតំលៃទៅលើភាពបន្សាំក្នុងលក្ខខណ្ឌប្រទេសកម្ពុជាភាគច្រើនជាពូជអាយុកាលលូតលាស់ខ្លី (ពូជស្រាល) និងពូជអាយុកាលលូតលាស់មធ្យម (ពូជកណ្តាល) ប៉ុន្តែចំពោះពូជធ្ងន់មិនសមស្របទៅនឹងលក្ខខណ្ឌនៃប្រទេស យើងឡើយ ។ ពូជដែលត្រូវបានណែនាំឱ្យប្រើប្រាស់មាន:

- ពូជ R៦១៩៧ និងពូជKao yuak១៨មកពីប្រទេសថៃដែលផលិតដោយក្រុមហ៊ុន East west seed
- ពូជ ៥៥ថ្ងៃ មកពីប្រទេសថៃ ផលិតដោយក្រុមហ៊ុន Chea tai seed សញ្ញាយន្តហោះ
- ពូជ Everst (F១) មកពីប្រទេសជប៉ុនផលិតដោយក្រុមហ៊ុន Takiiseed
- ពូជ wang jian មកពីចិនហុងកុង ដែលផលិតដោយ Hong kong Field Friend Agriculture Unite .Co ហើយកំពុងពេញនិយមទូទាំងប្រទេសកម្ពុជា ចាប់ពីឆ្នាំ២០០១ មក។



- ពូជជាច្រើនប្រភេទទៀតមកពីប្រទេសជប៉ុនផលិតដោយ ក្រុមហ៊ុនពីរគឺ Sakata Seed និង Kaneco Seed ដែលអាចដាំដុះបាន ។

## ៣-ការជ្រើសរើស និងរៀបចំដី

- អំពីប្រភេទដី: ផែថាវជាប្រភេទដំណាំយកមើមដែលលូតលាស់នៅក្នុងស្រទាប់ដីប៉ែកខាងលើ ម្យ៉ាងទៀតវាជាប្រភេទដំណាំដែលមានវដ្តជិវិតខ្លីដូចនេះតំរូវការដីដែលមានជីជាតិគ្រប់គ្រាន់ ។ លក្ខខណ្ឌដែលសមស្របសំរាប់ធ្វើការដាំដុះគឺដីធូរ ជ្រាបទឹកបានល្អ ស្រទាប់ដាំដុះជ្រៅដុះលើដីខ្សាច់ច្រើនជាងកណ្តោងជាពិសេស គឺដីល្បាយខ្សាច់ ដីល្បប់មាត់ស្ទឹង ព្រែក ទន្លេ វាមិនអាចដុះលូតលាស់លើប្រភេទដីឥដ្ឋបានឡើយ ប៉ុន្តែវាក៏អាចដុះលូតលាស់ល្អលើដីក្រហមខ្ពង់រាបដែរ ។





ជាទូទៅកំរិត pH ៦-៧,៥មានអំណោយផលល្អបំផុតសំរាប់ការដុះលូតលាស់ និង ទិន្នផលខ្ពស់ ។

- ការរៀបចំដី: ត្រូវរាស់ប្រមូលយកស្មៅ កាកសំណល់ផ្សេងៗចេញពីចំការ ហើយភ្ជួរឱ្យជ្រៅហាលដីឱ្យស្ងួតដើម្បីបន្ថយការដុះស្មៅនិងកត្តាចង្រៃដែលរស់ នៅក្នុងដីបន្ទាប់មករាស់បំបែកដីឱ្យល្អិតកៀរដីឱ្យស្មើ ។ ការភ្ជួររាស់ត្រូវធ្វើឱ្យបាន ២-៣ លើក ដើម្បីឱ្យដីមានបន្ទុកខ្យល់គ្រប់គ្រាន់ព្រមទាំងធ្វើឱ្យដីធូរជ្រាប ទឹកបានល្អ ហើយត្រូវលើករងឱ្យមានកំពស់២៥-៣០សម ទទឹងរង ១០០-១២០ សម បន្ទាប់មកយកជីគីមីប្រភេទ ១៥.១៥.១៥ ២០០គក្រ ជីធម្មជាតិ ១៥-១៨ តោន លើផ្ទៃដី ១ ហ.ត បាចលើរង ហើយរាស់លុបកៀរឱ្យស្មើ នឹងអាចដាំបាន ។



## ៤- របៀបដាំដុះ

ផៃថាវគេដាំវានឹងគ្រាប់ផ្ទាល់ ដូចនេះមុននឹងយកគ្រាប់ទៅដាំ ត្រូវយកគ្រាប់ពូជនោះដាក់ហាលថ្ងៃឱ្យក្តៅរយៈពេល ១-២ម៉ោង ក្រោយមកដាក់ត្រាំទឹក ៣-៤ម៉ោង នឹងលាងសំអាតគ្រាប់ឱ្យបានច្រើនលើកព្រមទាំងលាយថ្នាំការពារផ្សិតបន្តិចៗ(១គក្រ គ្រាប់ = ២ក្រាមថ្នាំ) ។ វិធីសាស្ត្រក្នុងការដាំដុះគឺយកគ្រាប់ពូជទៅដាំលើថ្នាល ផ្ទាល់ដោយដាក់ក្នុងជំរៅ២ ស.ម ជាមធ្យមក្នុងមួយគុម្ព ២គ្រាប់ ហើយចន្លោះជួរ នឹង គុម្ព ២០សម យ ២០សម ក្រោយពីដាំហើយយកចំបើងស្ងួតទៅពង្រាយគ្របពីលើផ្ទៃ រងឱ្យបាន ៧០ ទៅ ៨០% ដើម្បីការពារសំណើម នឹងភាពហាប់ណែននៃដីជួយឱ្យ ផៃថាវដុះលូតលាស់បានល្អ ប៉ុន្តែក្រោយពីដាំត្រូវស្រោចទឹកឱ្យជោគភ្លាម ។



## ៥-ការស្រោចស្រព

ការផ្តល់ទឹកបានគ្រាប់គ្រាន់ និងទៅតាមតំរូវការរបស់វា ធ្វើឱ្យដំណាំដុះលូតលាស់លឿន ប៉ុន្តែសេចក្តីត្រូវការមិនដូចគ្នាទាំងស្រុងនោះឡើយ គឺអាស្រ័យទៅតាមវគ្គលូតលាស់របស់វាដូចតទៅ:

- វគ្គដុះពន្លក: នៅក្នុងវគ្គនេះចាប់តាំងពីដាំរហូតដល់ឆៃថាវដុះ ១០០% វា ត្រូវការសំណើមដីថេរ តែមិនជោគជាំខ្លាំង កាលណាដីស្ងួតបណ្តាលឱ្យក្តាំងដីធ្វើ ឱ្យដំណុះមិនស្មើគ្នា ព្រមទាំងបាត់បង់ចំនួនដើមច្រើន ដូចនេះ គេត្រូវផ្តល់ទឹកព្រឹក ល្ងាច តាមវិធីសាស្រ្តជាច្រើនដែលធ្វើទៅបានដោយប៉ោតដោយម៉ាស៊ីនបូមទឹក ។





នៅក្នុងវគ្គនេះ កាលណាសំណើមដីសើមខ្លាំងលើសសេចក្តីត្រូវការ ធ្វើឱ្យកូនដំណាំរលួយឫសទៅវិញ ។

- វគ្គលូតលាស់ស្លឹកពិត: ក្រោយពីដុះពន្លក ១០០% រយ:ពេល ៧-១០ថ្ងៃ ឆៃថាវដុះបានស្លឹកពិត ២-៣ សន្លឹក វាត្រូវការទឹកកំរិតមធ្យមប្រហែលគ្នានឹងវគ្គដុះពន្លកដែរ ប៉ុន្តែទាបជាងបន្តិចកាលណាស្រោចទឹកខ្លាំងសំណើមដីខ្ពស់ធ្វើឱ្យគល់ កូនឆៃថាវប្រេះ អាចធ្វើឱ្យយឺតយ៉ាវ វគ្គកំណកំណើតមើម ។

- វគ្គកំណកំណើត និងពង្រីកមើម: ក្រោយពីដាំបានរយ:ពេល ១៥-១៨ថ្ងៃ គេសង្កេតឃើញឆៃថាវចាប់ផ្តើមពង្រីកគល់ប៉ោងបន្តិចៗ ពេលនោះ វាត្រូវការទឹក និង សារធាតុចិញ្ចឹមកាន់តែកើនឡើងៗ រហូតដល់ពេលប្រមូលផល ដូចនេះត្រូវបង្កើនការស្រោចទឹកឱ្យខ្លាំងជាងវគ្គនានាអាចធ្វើឱ្យទិន្នផលឆៃថាវកាន់តែកើនឡើង ។

## ៦-ការជ្រំជ្រួយដី ដកស្មៅ



ដើម្បីឱ្យដីធូរ ព្រមទាំងទប់ស្កាត់ការដុះលូតលាស់នូវស្មៅចង្រៃហើយនឹងការលូតលាស់ប្រពន្ធ័ឫសតំបូងត្រូវដករំលោះកូនឆៃថាវចេញទុកតែមួយដើមក្នុង១គុម្ព ព្រម ទាំងដកស្មៅចេញ ហើយយកកូនចបមុខតូចជ្រំុដីឱ្យផុសក្បែរៗគុម្ពពេញផ្ទៃរង ហើយផ្អាកការស្រោចទឹករយៈពេល ១ថ្ងៃ ធ្វើឱ្យដីនោះស្ងួតខ្យល់ចេញចូល បានល្អ រយៈពេលសមស្របក្នុងការជ្រំជ្រួយដី គឺធ្វើឡើងក្រោយពីដាំបានចំនួន ១៥-១៨ថ្ងៃ កាលណាពន្យារពេល ជ្រំជ្រួយដីទុកឱ្យឆៃថាវពង្រីកមើមកាន់តែធំអាចរំខានដល់ការវិវឌ្ឍន៍នៃប្រពន្ធ័ឫសរបស់វាធ្វើឱ្យមើមតូចហើយខ្លី ។ ឆៃថាវជាប្រភេទដំណាំ ត្រូវការជីជាតិច្រើនប្រភេទព្រមទាំងសារធាតុរ៉ែផ្សេង ៗ

### ៧-ការដាក់ជីបំប៉ន

ឆៃថាវជាប្រភេទដំណាំត្រូវការជីជាតិច្រើនប្រភេទព្រមទាំងសារធាតុរ៉ែផ្សេង ៗ







ប៉ុន្តែជាពិសេសគឺសារធាតុអាសូត(N) ផូស្វ័រ(P)ប៉ូតាស្យូម(K) និងកាល់ស្យូម(Ca) ដូចនេះកាដាក់ជីត្រូវ ជ្រើសរើសប្រភេទជីណាដែលមានសារធាតុ N.P.K នឹង កាល់ស្យូមដើម្បីឱ្យមានធាតុកាល់ស្យូមគេច្រើនប្រើលាមកសត្វជាពិសេសលាមកមាន់ដាក់មុនដាំលើដី១ ហាត ដាក់ចំនួន ៨០០០ - ១០.០០០ គក្រក្រៅពីនោះទៀតគេអាច ប្រើជីលាមកជ្រូកពុកផុយយូរឆ្នាំក៏បានដែរ។ យោងទៅតាមតំរូវការ និងប្រភេទសារធាតុគេបែងចែកការដាក់ជីបំប៉នចំនួន ៤លើកគឺ:

- បំប៉នលើកទី១ ប្រើជីអ៊ុយរ៉េលាយទឹកស្រោចដោយប្រើចំនួន ២៥-៣០ គក្រលាយទឹក ២០លីត្រ លើ ផ្ទៃដី ១០ម$^{2}$ ហើយស្រោចទឹកលាងតាមក្រោយ ១ហ.ត គេប្រើទំងន់ ២៥-៣០គក្រ រយៈពេល ១០ថ្ងៃក្រោយដាំ។

- បំប៉នលើកទី២ ប្រើជី ១៥ ១៥ ១៥ ចំនួន ២០០ក្រាមលើផ្ទៃដី ១០ម$^២$ ១ហ.ត ២០០គក្រ ដាក់ក្រោយជ្រំជ្រួយដី ១៥-១៨ថ្ងៃក្រោយដាំវិធីដាក់គឺតាមចន្លោះគុម្ពហើយជ្រំដីលុបឱ្យជិត ។

- បំប៉នលើកទី៣ ប្រើជីអ៊ុយរ៉េ ៤០-៥០ក្រាម លាយទឹក២០លីត្រស្រោចឱ្យជោគលើផ្ទៃដី១០ម$^២$ ហើយស្រោចទឹកលាងតាមក្រោយរយៈពេល ២៥-៣០ថ្ងៃ ក្រោយដាំ។

- បំប៉នលើកទី៤ គេប្រើជីពីរប្រភេទរួមគ្នាក្នុងករណីធ្វើទៅបាន គឺជីអ៊ុយរ៉េចំនួន ៣០គក្រ និងជីប៉ូតាស្យូម ៥០គ.ក្រ ដោយបញ្ចូលគ្នាហើយដាក់តាមចន្លោះគុម្ពរយៈពេល ៤០ ថ្ងៃ ក្រោយពីដាំធ្វើឱ្យផៃថាវមើមធំហើយមានគុណភាពល្អ។

## III. អំពីសត្វល្អិតចង្រៃ និងការការពារ

ដំណាំផៃថាវជាធម្មតាត្រូវបានរងការបំផ្លាញពីសត្វល្អិតចង្រៃសំខាន់ៗចំនួន ៤ប្រភេទគឺ:

១- ដង្កូវយោលទោង: ជាសត្រូវយ៉ាងចំបងវាស៊ីបំផ្លាញជាលិកាស្លឹកធ្វើឱ្យ ស្លឹកផៃថាវលែងលូតលាស់បានហើយបាត់បង់ ១០០%។ នៅប្រទេសកម្ពុជាយើងការបំផ្លាញច្រើនចាប់ផ្ដើមពីចុងខែមករា ដល់ខែឧសភាក្រៅពីនេះវត្តមានរបស់វាត្រូវថយចុះមកវិញ ។ ដើម្បីការពារ និងកំចាត់ដង្កូវប្រភេទនេះគេត្រូវសិក្សា អំពីវត្តមានមេចំណាស់របស់វាគឺមេអំបៅកាលណាមានមេអំបៅហើរក្នុងចំការពេលល្ងាចមិនយូរនឹងមានដង្កូវស៊ីបំផ្លាញដូចនេះគេត្រូវទប់ទល់ជាមុនទៅតាមលក្ខណៈដែលអាចធ្វើទៅ បានជាពិសេសគឺវិធានការគីមី ។



២- ដង្កូវស៊ីរូងកំពូល វាមានរាងតូចៗប្រហែលនឹងដង្កូវយោលទោងដែរ តែមានមាឌធំហើយវែងជាងពណ៌ប្រផេះ មានរោមបន្តិច ៗ វាស៊ីស្លឹកដោយពុំបន្សល់ទុកនូវភ្នាសដូចដង្កូវយោលទោងឡើយព្រមទាំងលក្ខណៈជាហ្វូងផ្តុំនៅនឹងត្រួយ។



៣- ដង្កូវកាត់ដើម ដង្កូវមានមាឌធំវែងៗពណ៌ខ្មៅច្រើនជ្រកពួននៅក្នុងចំការដំណាំមេអំបៅរបស់វាពងដាក់លើស្មៅ ឬដីមុនពេលដាំដំណាំក្រោយពីដំណាំដុះក្នុង ដំណាក់កាលកូនសំណាប វាចាប់ផ្តើមញាស់ ហើយកាត់ស៊ីជាចំណីអាហាររបស់វានៅ ពេលយប់ វាធ្វើឱ្យបាត់បង់ចំនួនដើមច្រើនក្នុងចំការដាំដុះ ។

៤- សត្វទាគូ: វាជាសត្វល្អិតចង្រៃយ៉ាងខ្លាំងព្រោះ ក្នុង១វដ្តជីវិតរបស់វាចាប់ ពីកូនញាស់ដល់មេចំណាស់ត្រូវស៊ីបំផ្លាញដំណាំជាប្រចាំដូចជា:

- ដំណាក់កាលកូនញាស់: មេចំណាស់ពងដាក់លើថ្នាលក្បែរគល់ដំណាំក្រោយពីវាញាស់ទៅជាកូនដង្កូវ តែងតែស៊ីបំផ្លាញឫស នឹងមើមផែថាវដែលកសិករ យើងហៅថាកណ្តៀរដីស៊ី ធ្វើឱ្យដំណាំស្រពោនបន្ថយការលូតលាស់ដើមត្រូវខូចខាត យ៉ាងខ្លាំង ជាពិសេសនៅរដូវក្តៅ ។

- ដំណាក់កាលពេញវ័យ: មេចំណាស់តូចៗ មានស្លាបរឹងប៉ុនៗជើងធូបរស់លក្ខណ:ជាក្រុមៗ លោតដោយផ្ទាត់ជើងរបស់វា សត្វនេះស៊ីទំលុះស្លឹកធ្វើឱ្យស្លឹករ ទុះៗដូចស្បៃ ស្លឹកក្រិនលែងលូតលាស់ អាចធ្វើឱ្យបាត់បង់ទិន្នផលយ៉ាងច្រើនក្នុង១ឆ្នាំៗ ការបំផ្លាញខ្លាំងចាប់ពី ខែ កុម្ភ: ដល់ខែ មេសាជារៀងរាល់ឆ្នាំ ។ ដើម្បីការពារ នឹងកំចាត់ដង្កូវប្រភេទនេះគេត្រូវអនុវត្តវិធានការយ៉ាងច្រើនដូចជា:

- ការផ្លាស់ប្តូរដី:ក្រោយពីប្រមូលផលផែថាវហើយ ត្រូវបាចថ្នាំប្រភេទ Furadan ក្នុងកំរិត ១០-១៥គ.ក្រ /ហ.ត ហើយភ្ជួរលុប ។



- ការជ្រើសរើសរដូវ រដូវមានទំនាក់ទំនងគ្នាជានិច្ចទៅនឹង ការកកើតនៃកត្តាចង្រៃ ព្រោះវាតែងពង្រីកពូជពង្សរបស់វានៅរដូវក្តៅ ហើយដំណាំមិនទាមទារនូវ សីតុណ្ហភាពក្តៅខ្លាំងឡើយ ។

- ការធ្វើអនាម័យចំការ សំអាតស្មៅទាំងក្នុងនិងជុំវិញចំការឱ្យបានស្អាតព្រោះវាជាជំរករបស់ភ្នាក់ងារចង្រៃគ្រប់ប្រភេទ ។

- ការអនុវត្តន៍វិធានការគីមី ក្នុងករណីមានដង្កូវ ៤ប្រភេទខាងលើគេប្រើប្រាស់ ថ្នាំគីមីពុលកសិកម្មក្នុងការកំចាត់ ដូចជាយកមកលាយទឹកបាញ់ឬបាចទៅក្នុងថ្នាលពេលសត្វល្អិតស្ថិតក្នុងដំណាក់កាលកូនញាស់ទើបមានប្រសិទ្ធិភាពល្អ ។





## IV. ការប្រមូលផល

ការប្រមូលផលត្រូវគិតអំពីវដ្តជីវិតរបស់វា ព្រមទាំងតំរូវការទីផ្សារ កាលណា ដកមើមឆៃថាវមិនទាន់គ្រប់អាយុកាល ត្រឹមត្រូវធ្វើឱ្យបាត់បង់ទិន្នផលព្រមទាំង មិនអាចរក្សាទុកបានយូរផងដែរ ព្រោះវាខ្ចីពេកប៉ុន្តែបើកាលណាពន្យាពេលដកធ្វើ ឱ្យមើមឆៃថាវចាស់ស្កោតក៏អាចបាត់បង់ទិន្នផល និងគុណភាពដែរ ។ ដូចនេះដើម្បី ប្រមូលផលទៅតាមស្តង់ដារគឺ គេពិនិត្យមើលទៅលើពណ៌នៃស្លឹកវាប្រែពណ៌បៃតង ខ្ចីទៅបៃតងចាស់ កំពូលត្រួយរបស់វាលែងលូតលាស់ដើមប្រែពណ៌ពីសខ្ចីទៅសប្រផេះ ហើយរលោងគ្មានជាប់ឫសពេលដកនោះ ជាដំណាក់កាលត្រូវប្រមូលផល ។



របៀបប្រមូលផលគឺដកយកមើមឆៃថាវដាក់តំរៀបនៅនឹងចំការ ក្រោយមកកាត់ស្លឹកចេញហើយជញ្ជូនទៅកាន់ទីត្រជាក់មិនត្រូវដាក់ហាលថ្ងៃឡើយ ។ កាលណាគេបញ្ជូនទៅកាន់ទីផ្សារជិតៗ ត្រូវលាងទឹកសំអាតមើមជាមុនសិន ប៉ុន្តែក្នុងករណី ត្រូវដឹកទៅកាន់តំបន់ឆ្ងាយៗ មិនត្រូវលាងទឹកឡើយ ព្រោះអាចបណ្តាលឱ្យជាំរលាត់ សំបក ទុកមិនបានយូរ ។ ប៉ុន្តែដោយឡែកសំរាប់ការដឹកជញ្ជូន ឬការរក្សាទុកក្នុង ប្រពន្ធ័បន្ទប់ត្រជាក់គេត្រូវលាងទឹកសំអាតឱ្យស្អាតជាមុន បន្ទាប់មកដាក់បញ្ចូល ទៅក្នុងកន្ត្រកផ្លាស្ទិកតាមលំដាប់លំដោយកន្ត្រកនោះមានរន្ធអាចជ្រាបចំហាយត្រជាក់ចូលទៅក្នុងបានហើយ យកទៅរក្សាទុករយៈពេល ៤០ម៉ោង ហើយបញ្ចុះសីតុណ្ហភាពឱ្យក្រោមសូន្យអង្សារបូនលេខ (-៤ °C) ដើម្បីសំលាប់ពួកមីក្រូសរីរាង្គ និងបាក់តេរីផ្សេងៗ ដែលបណ្តាលឱ្យឆៃថាវរលួយ ។ ជាធម្មតាទិន្នផល ជាមធ្យមទៅតាមប្រភេទពូជនិងរដូវកាលដាំដុះ ប៉ុន្តែទោះជាយ៉ាងណានៅក្នុង ប្រទេសកម្ពុជាយើងអាចទទួលបានពី ២៨-៣២ តោន/ហ.ត ។